# កត្តាជំរុញសំខាន់ៗក្នុងកំណើនផលិតភាពនៅក្នុងប្រទេសកម្ពុជា

បទបង្ហាញដោយ លោក ច័ន្ទ សុផល

នាយក មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS)

៣ វិច្ឆិកា ២០១៩

# អ្វីទៅជាផលិតភាព?

- ✓ ផលិតភាពពលកម្ម
- ✓ ផលិតភាពកត្តាផលិតកម្មផ្សេងទៀត
- ✓ ផលិតភាពមូលធន
- ✓ ផលិតភាពឧស្សាហកម្ម
- ✓ ផលិតភាពសេដ្ឋកិច្ចជាតិ

# កត្តាកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា

**កត្តាសង្គម**

1. ស្ថានភាពគ្រួសារ
2. ចំណាយក្នុងការរស់នៅ

**កត្តាសេដ្ឋកិច្ច**

3. អតិផរណា
4. ផលិតភាពពលកម្ម
5. ភាពប្រជែងឈ្នះនៃប្រទេស
6. ស្ថានភាពទីផ្សារការងារ
7. ភាពចំណេញនៃវិស័យ

**ផលិតភាពពលកម្ម ដោយគិតតាមការយកតម្លៃបន្ថែមក្នុងវិស័យទាំងមូល មកចែកនឹងចំនួនកម្មករមានភាពងាយស្រួលក្នុងការគណនា**

**ប៉ុន្តែមិនឆ្លុះបញ្ចាំងផលិតភាពពេញលេញទេ**



# ផលិតភាពពលកម្ម

ផលិតភាពពលកម្មសំដៅលើការផលិតបានច្រើនជាងមុនគិតក្នុងចំនួនមនុស្សដដែល។ វាជាកត្តាសំខាន់បំផុតសម្រាប់ការឡើងប្រាក់ឈ្នួលដោយមិនប៉ះពាល់ដល់ភាពប្រដែងឈ្នះនៃវិស័យ និងសេដ្ឋកិច្ចជាតិ។

## ផលិតភាពពលកម្ម

កត្តាដែលធ្វើឱ្យផលិតភាពពលកម្មកើនឡើងមានច្រើន ដូចជា

1. ការកើនឡើងជំនាញ និង ទេព្យកោសល្យ
2. ប្រសិទ្ធភាពឧបករណ៍និងគ្រឿងចក្រ
3. ការគ្រប់គ្រងមានប្រសិទ្ធភាពជាងមុន
4. កម្មករមានសុខភាពល្អជាងមុន ឬមានទឹកចិត្តធ្វើការជាងមុន (ប្រាក់ឈ្នួលកើនឡើង)
5. ផលិតកម្មមានដំណើរការជាប់លាប់ល្អ មិនសូវមានការរំខានដោយប្រការណាមួយ ឬមានកូដកម្មតិចជាងមុន មានការធ្វើដំណើរប្រសើរជាងមុន។ល។

# កត្តាជំរុញសំខាន់ៗក្នុងកំណើនផលិតភាពនៅក្នុងប្រទេសកម្ពុជា

## កត្តាខាងក្នុងខ្លួន

**(របស់កម្មករ និយោជិត)**

1) សុខភាព
2) ការអប់រំ
3) ជំនាញ បំណិន
4) វិន័យក្នុងខ្លួន
5) ទឹកចិត្តចង់មានបាន

## កត្តាខាងក្រៅ

**(និយោជក និងបរិស្ថានធុរកិច្ចអំណោយផល)**

1) ការបណ្ដុះបណ្ដាលកម្មករ និយោជិត
2) ការបំពាក់គ្រឿងបរិក្ខា និងបច្ចេកវិទ្យាល្អ និងសមស្រប
3) ទីកន្លែងធ្វើការប្រកបដោយផាសុខភាព
4) ប្រព័ន្ធគ្រប់គ្រងល្អ និងលើកទឹកចិត្តសមស្រប
5) បរិស្ថានធុរកិច្ចអំណោយផល

**សន្ទស្សន៍ការកែលំអប្រព័ន្ធភស្តុភា នៅកម្ពុជា និងប្រទេសជាគូប្រកួតមួយចំនួន (2018) បង្ហាញថាកម្ពុជា មានភាពប្រសើរជាងឡាវ ណេប៉ាល់ ភូមា និងបង់ក្លាដេស ដែលជាចំណុចល្អ សម្រាប់ភាពប្រជែងឈ្នះនៃប្រទេស  ពោលគឺដូចឆ្នាំមុនដែរ។**

**(តួលេខទាបជាងមានន័យថាមានបរិស្ថានអំណោយផលជាង)**




ប្រភព: World Bank Logistics Performance Index Report 2018 (Connecting to Compete 2016), ដោយដាក់ចំណាត់ថ្នាក់ប្រទេសចំនួន 160

**ភាពងាយស្រួលក្នុងការប្រកបធុរកិច្ច**នៅកម្ពុជា និងប្រទេសជាគូប្រកួតមួយចំនួន (2018) បង្ហាញថាកម្ពុជា មានភាពប្រសើរជាងឡាវ ប៉ាគីស្ថាន ភូមា និងបង់ក្លាដេស ដែលជាចំណុចល្អ សម្រាប់ភាពប្រជែងឈ្នះនៃប្រទេស **ពោលគឺដូចឆ្នាំមុនដែរ។**

**(តួលេខទាបជាងមានន័យថាមានបរិស្ថានអំណោយផលជាង)**




ប្រភព: World Bank, Doing Business Report 2018 ដោយដាក់ចំណាត់ថ្នាក់ប្រទេសចំនួន 190